**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៣២៩ សហវ

# ប្រកាស

## ស្តីពី

## ការប្រើប្រាស់តារាងពន្ធគយថ្មី

### ឧបនាយករដ្ឋមន្ត្រី

### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១៩៦ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១
- បានឃើញអនុក្រឹតលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការកែសំរួលអត្រាពន្ធ និងអាករលើទំនិញមួយចំនួន



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone 855-23-724 664 Fax : 855-23-427 798

## សំរេច

**ប្រការ១** : រាល់មុខទំនិញនាំចេញ នាំចូលត្រូវជាប់ពន្ធនាំចូល អាករនាំចេញ អាករពិសេស និងអាករលើតំលៃបន្ថែមដូចមានចែងលំអិតក្នុងតារាងពន្ធគយនេះ ។

**ប្រការ២** : ទំនិញនៅក្នុងបញ្ជីទំនិញដាក់បញ្ចូលក្នុងសេម៉ា CEPT សំរាប់ AFTA ដែលមានភ្ជាប់នៅក្នុងតារាងពន្ធគយឆ្នាំ២០០០ ត្រូវស្ថិតនៅជាធរមាន ។

**ប្រការ៣** : បទបញ្ញត្តិផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤** : ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០១ ខាងមុខនេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០០១

គាត ឈន់

ចំលងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង
- ទីចាត់ការគយ និងរដ្ឋាករ
  "ដើម្បីអនុវត្ត"
- ឯកសារ- កាលប្បវត្តិ